ឬទម្រង់នៃរំលោភបំពានដទៃទៀត ឬស្ត្រីដែលជួបការពិបាកជាមួយនឹងការផ្លាស់ប្តូរនេះ។ ផ្តល់ឬសម្របសម្រួលឲ្យទទួលបានការគាំទ្រ និងសេវាការពារត្រឹមត្រូវ។

១២. ទទួលស្គាល់ និងការពារសិទ្ធិជនជាតិដើមភាគតិច ទទួលបានដីធ្លីតាមប្រពៃណី។ សកម្មភាពអភិវឌ្ឍន៍ ដូចជាអាជីវកម្មកាប់ឈើ និងរុករករ៉ែ ដែលអាចបង្កផលប៉ះពាល់មកលើសហគមន៍ជនជាតិដើមភាគតិច មិនអាចដំណើការទៅបានទេ រហូតទាល់តែសហគមន៍ដែលរងផលប៉ះពាល់ទាំងនោះ ត្រូវបានជម្រាបដំណឹងនិងមានការយល់ព្រមជាមុន។ នីតិវិធីទាំងអស់ ដែលបង្កើតឡើងសម្រាប់ការពិគ្រោះយោបល់ និងស្វែងរកការយល់ព្រមពីជនជាតិដើមភាគតិច ត្រូវធានាថា ស្ត្រីចូលរួមយ៉ាងពេញលេញ ដោយសិទ្ធិស្មើគ្នានឹងសមាជិកផ្សេងៗរបស់សហគមន៍។ នីតិវិធីទាំងនេះ រួមមានការផ្តល់ព័ត៌មានផង ត្រូវតែសមស្រប (ពោលគឺ ប្រើប្រាស់ភាសាជនជាតិដើមភាគតិច ផ្តល់ពេលវេលាសម្រាប់កសាងមតិយល់ព្រមភាគច្រើន និងប្រើទីកន្លែងសមស្របនិងអាចចេញចូលបាន)។ បទដ្ឋានស្តីពីការការពារទាំងនេះ ត្រូវមានចែងក្នុងច្បាប់ជាតិ ដែលច្បាប់នេះតាក់តែងឡើងដោយមានការចូលរួមយ៉ាងពេញលេញពីជនជាតិដើមភាគតិច។

១៣. ធានាថាប៉ូលិស និងកម្លាំងសន្តិសុខផ្សេងៗ ដែលពាក់ព័ន្ធក្នុងការបណ្តេញចេញ ឬការតវ៉ាទាក់ទងជម្លោះដីធ្លី ត្រូវអនុវត្តយ៉ាងតឹងរឹងតាមបទដ្ឋានអន្តរជាតិ ដោយដាក់កំហិតការប្រើកម្លាំង ដោយមន្ត្រីប្រតិបត្តិច្បាប់។

**ចំពោះសហគមន៍អន្តរជាតិ**

ម្ចាស់ជំនួយជាឧបតោភាគី និងពហុភាគី ត្រូវធានាថា ពួកគេមិនគាំទ្រលើគម្រោង និងកម្មវិធីណាដែលនាំឲ្យ ឬជាបច្ច័យដល់ការរំលោភសិទ្ធិមនុស្ស រួមមានការបណ្តេញចេញដោយបង្ខំ។

ម្ចាស់ជំនួយជាឧបតោភាគី និងពហុភាគី ត្រូវធានាថា រាល់ការផ្តល់ឬពិចារណាគាំទ្រផ្នែកបច្ចេកទេសឬហិរញ្ញវត្ថុ សម្រាប់គម្រោងឬកម្មវិធីដែលទាក់ទងនឹងការជម្លៀស និងការតាំងទីលំនៅថ្មីរបស់សហគមន៍ ពួកគេត្រូវអនុវត្តដោយសមស្របទៅតាមបទដ្ឋានសិទ្ធិមនុស្ស។ ទាំងនេះរួមមាន ៖

- ធ្វើការប្តេជ្ញាចិត្តដោយច្បាស់ៗថា ពួកគេមិនគាំទ្រសកម្មភាពដែលជាបុព្វហេតុ ឬនាំឲ្យមានការ រំលោភសិទ្ធិមនុស្សទេ។

- ទទួលបានការធានាប្រកបដោយប្រសិទ្ធិភាពពីរាជរដ្ឋាភិបាលកម្ពុជាថា នឹងគ្មានការបណ្តេញចេញដោយបង្ខំ ឬការរំលោភសិទ្ធិមនុស្សនានា ក្នុងគម្រោងឬកម្មវិធីណាមួយដែលពួកគេកំពុងតែឧបត្ថម្ភគាំទ្រ។

- ធ្វើការជាមួយរាជរដ្ឋាភិបាល ដើម្បីធានាថា រាល់គម្រោងឬកម្មវិធីដែលពាក់ព័ន្ធនឹងការជម្លៀស ឬតាំងទីលំនៅថ្មី ត្រូវរៀបចំនិងអនុវត្តឲ្យបានសមស្របនឹងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ទៅតាមបទដ្ឋានសិទ្ធិមនុស្ស រួមមានសិទ្ធិលំនៅឋានគ្រប់គ្រាន់និងគ្មានការរើសអើង និងសមភាព។

- ធ្វើការជាមួយរាជរដ្ឋាភិបាល ដើម្បីធានាថា គ្មានការអភិវឌ្ឍន៍លើដីជាប្រពៃណី ដោយគ្មាន ការជម្រាបព័ត៌មាន និងការយល់ព្រមជាមុនពីជនជាតិដើមភាគតិច។

លិបិក្រម: ASA 23/007/2011
វិច្ឆិកា ២០១១

Amnesty International
International Secretariat
Peter Benenson House
1 Easton Street
London WC1X ODW
United Kingdom

amnesty.org/demand-dignity




សូមអានរបាយការណ៍អំពីការបណ្តេញចេញ និងការតស៊ូក្នុងប្រទេស កម្ពុជា: ស្ត្រីប្រាំនាក់និយាយរឿងរបស់ខ្លួន (លិបិក្រម: ASA 23/006/2011) at www.amnesty.org

**HOUSING IS A HUMAN RIGHT**

**AMNESTY INTERNATIONAL**

អង្គការលើកលែងទោសអន្តរជាតិ គឺជាចលនាជាសាកលមួយ ដែលមាន អ្នកគាំទ្រ សមាជិក និងសកម្មជន ជាងប្រាំលាននាក់ នៅក្នុងប្រទេស ជាង ១៥០ និងដែនទឹកដែនដី ដែលបានធ្វើយុទ្ធនាការណ៍ ដើម្បីបញ្ចប់ អំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

ទស្សនៈរបស់យើង គឺចង់អោយមនុស្សគ្រប់រូប ទទួលបានសិទ្ធិ ដែលតម្កល់ ក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ

យើងខ្ញុំជាអង្គការដែលឯករាជ្យពីរដ្ឋាភិបាល មនោគមវិជ្ជា ផលប្រយោជន៍សេដ្ឋកិច្ច ឬសាសនា។ យើងខ្ញុំទទួលបានមូលនិធិ ជាចំបងពីសមាជិកភាពរបស់យើង និងអំណោយសាធារណៈ:

លំនៅឋាន គឺជាសិទ្ធិមនុស្ស
AMNESTY
INTERNATIONAL

# ការបណ្តេញចេញ និងការតស៊ូនៅក្នុងប្រទេសកម្ពុជា

## ស្ត្រីប្រាំនាក់ប្រាប់រឿងរបស់ខ្លួន

## អនុសាសន៍

ប្រជាពលរដ្ឋរាប់សែននាក់នៅទូទាំងប្រទេសកម្ពុជា ត្រូវបានបណ្តេញចេញដោយបង្ខំ ពាសពេញប្រទេស កម្ពុជា។ ក្នុងចន្លោះឆ្នាំ១៩៩០ និង២០១១ ចំពោះតែរាជធានីភ្នំពេញមួយប៉ុណ្ណោះ មានប្រជាពលរដ្ឋ ក្នុងរាជធានីប្រហែលដប់ភាគរយ ត្រូវបានគេ បណ្តេញចេញ។ គម្រោងអភិវឌ្ឍន៍ និងជម្លោះដីធ្លី គឺជាដើមហេតុនៃការបណ្តេញចេញ ដែលទីបំផុតសុខមាលភាពរបស់សហគមន៍ ត្រូវទទួលរងនូវផលប៉ះពាល់ ដោយសារតែតម្រូវការរបស់ក្រុមហ៊ុនពាណិជ្ជកម្មធំៗ។

> ក្នុងអំឡុងពីរទសវត្សរ៍កន្លងមកនេះ ការបណ្តេញចេញដោយបង្ខំ ការរំលោភច្បាមយកដីធ្លី និងការកេងប្រវ័ញ្ចលើធនធានធម្មជាតិមិនបានជួយផ្តល់ផលចំណេញអ្វីឱ្យដល់ប្រទេសកម្ពុជានេះកាត់បន្ថយភាពក្រីក្រទេ។

លំនៅឋាន និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ កំពុងតែទទួលរងនូវការគំរាមកំហែងផងដែរ ដោយសារការកាប់បំផ្លិចបំផ្លាញយ៉ាងឆាប់រហ័សនៃព្រៃឈើ និងធនធានធម្មជាតិដទៃទៀតរបស់ប្រទេសកម្ពុជា។ នៅពេលធនធានទាំងនេះទទួលរងមហន្តរាយ ក្រុមគ្រួសារដែលពឹងលើ ធនធានទាំងនោះសម្រាប់ចិញ្ចឹមជីវិតត្រូវបានបង្ខិតបង្ខំឱ្យចាកចេញឆ្ងាយដើម្បីរកមធ្យោបាយផ្សេង សម្រាប់ចិញ្ចឹមជីវិត។ អ្នកដែលងាយរងគ្រោះជាពិសេសនោះគឺជនជាតិដើមភាគតិចមួយចំនួនរបស់ ប្រទេសកម្ពុជាដែលជីវភាពសេដ្ឋកិច្ច សង្គម និងជំនឿរបស់ពួកគេផ្សារភ្ជាប់ទៅនឹងព្រៃឈើដែលមិន អាចកាត់ផ្តាច់ពីគ្នាបាន។

ក្នុងអំឡុងពីរទសវត្សរ៍កន្លងមកនេះ ការបណ្តេញចេញដោយបង្ខំ ការរំលោភច្បាមយកដីធ្លី និងការកេងប្រវ័ញ្ចលើធនធានធម្មជាតិ មិនបានជួយផ្តល់ផលចំណេញអ្វីឱ្យដល់ប្រទេសកម្ពុជានេះកាត់បន្ថយ ភាពក្រីក្រទេ។ អំពើទាំងនេះផ្ទើននៅចំពោះមុខការប្តេជ្ញាចិត្តច្រំដែលៗរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុង ការកាត់បន្ថយភាពក្រីក្រ និងក្នុងការលើកកម្ពស់ការគោរពនីតិរដ្ឋនិងសិទ្ធិមនុស្ស ដែលរាជរដ្ឋាភិបាលកម្ពុជា បានធ្វើនៅចំពោះមុខដៃគូរអភិវឌ្ឍន៍របស់ខ្លួនជាឧបត្ថម្ភភាគីនិងពហុភាគី។ ម្ចាស់ជំនួយទាំងនេះ បានផ្តល់ទឹកប្រាក់ជាជំនួយរាប់រយកោដិដុល្លារចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងបារីសពីឆ្នាំ១៩៩១មក។

វិច្ឆិកា ២០១១
លិបិក្រម: ASA 23/007/2011

## ការការពារតាមផ្លូវច្បាប់ ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ

ប្រទេសកម្ពុជា ជាប់កាតព្វកិច្ចក្រោមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ
មានជាអាទិ៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និវប្បធម៌
និងកតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ
ដើម្បីទប់ស្កាត់និងការពារប្រជាពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ។
ជាផ្នែកមួយនៃកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរពនិងការពារសិទ្ធិមានលំនៅឋានសមរម្យ
អាជ្ញាធរកម្ពុជាត្រូវតែធានាថា មានវិធានការការពារតាមនីតិវិធី
មុននឹងអនុវត្តរាល់ការបណ្តេញចេញណាមួយ។ វិធានការទាំងនោះ
រួមមានការពិគ្រោះយោបល់ដោយស្មោះត្រង់ជាមួយសហគមន៍ដែលរងការប៉ះពាល់
ដើម្បីស្រាវជ្រាវ រកលទ្ធភាពជាជម្រើសក្រៅពីការបណ្តេញចេញ
ដោយត្រូវជូនដំណឹងនិងផ្តល់ដំណោះស្រាយផ្លូវច្បាប់ឲ្យបានគ្រប់គ្រាន់
និងផ្តល់សំណងសម្រាប់ការបាត់បង់ និងផ្តល់លំនៅឋានសមរម្យ
ចំពោះអ្នកទាំងឡាយដែលមិនអាចផ្គត់ផ្គង់ខ្លួនឯងបាន។

ក៏ប៉ុន្តែភាពទន់ខ្សោយនៃស្ថាប័នតុលាការ និងរដ្ឋបាលប្រទេសកម្ពុជា
ជាញឹកញយខកខានមិនបានលើកកម្ពស់សិទ្ធិគ្រួសារ
និងសហគមន៍ដែលបានប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ
ដោយសារអ្នករំលោភច្បាមយកដីធ្លីនិងអ្នកដែលទទួលផលពីសម្បទានដីសេដ្ឋកិច្ចនោះ
មានភ្ជាប់ទំនាក់ទំនងល្អ។ លើសពីនេះទៀត អ្នកប្រព្រឹត្តបទល្មើស
កម្រត្រូវបាននាំខ្លួនឡើងតុលាការកាត់ទោសចំពោះបទរំលោភសិទ្ធិមនុស្សដែល
ពួកគេបានប្រព្រឹត្តណាស់។

ទោះបីច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០
មានការការពារសិទ្ធិខាងផ្លូវច្បាប់ខ្លះៗក៏ដោយ
ក៏ច្បាប់ទាំងនេះខកខានមិនបានការពារក្រុមប្រជាពលរដ្ឋទាំងអស់ពីការបណ្តេញ
ចេញដោយបង្ខំដែរ។ ប្រជាពលរដ្ឋដែលមានការកាន់កាប់ដីដែលគ្មានប័ណ្ណកម្មសិទ្ធិ
(ដូចជាប្រជាពលរដ្ឋដែលកំពុងរស់ក្នុងទីលំនៅមិនស្របច្បាប់លើដីសាធារណៈ)
បានទទួលការការពារតិចតួចណាស់ក្រោមច្បាប់ទាំងនេះ។
ការការពារតាមផ្លូវច្បាប់ដែលមានស្រាប់ ក៏អនុវត្តមិនល្អផងដែរ។

## ជនជាតិដើមភាគតិច

ច្បាប់ភូមិបាល ផ្តល់សិទ្ធិអំណាចឲ្យរដ្ឋ ដើម្បីផ្តល់កម្មសិទ្ធិដីសមូហភាពដល់
សហគមន៍ជនជាតិដើមភាគតិច។ កម្មសិទ្ធិសមូលហភាព
រាប់បញ្ចូលសិទ្ធិនិងការការពារទាំងអស់នៃកម្មសិទ្ធិឯកជន។ ស្ថិតក្រោមច្បាប់នេះ
សហគមន៍ជនជាតិដើមភាគតិច មានសិទ្ធិគ្រប់គ្រងចាត់ចែងដីធ្លីរបស់ខ្លួន
តាមប្រពៃណីរបស់ពួកគេ ដែលជាវិធានការការពារបណ្តោះអាសន្ន
មុនពេលធ្វើការចុះបញ្ជីសហគមន៍ជាផ្លូវការ។ ទោះជាយ៉ាងណាក៏ដោយ
តាមការអនុវត្តជាក់ស្តែង នីតិបញ្ញត្តិទាំងនេះ មិនត្រូវបានគេអើពើដដែលៗ។

សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា
ត្រូវបានការពារក្រោមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ
ដែលប្រទេសកម្ពុជាបានឲ្យសច្ចាប័ន។ សិទ្ធិទាំងនោះក៏ត្រូវបានការពារ
ក្រោមសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិជនជាតិដើមភាគតិច
ដែលប្រទេសកម្ពុជាបានអនុម័តយក
រួមជាមួយបណ្តារដ្ឋចំនួន១៤៣ផ្សេងទៀតនៅក្នុងឆ្នាំ២០០៧។
សេចក្តីប្រកាសបានគូសបញ្ជាក់អំពីសិទ្ធិជនជាតិដើមភាគតិច
ដើម្បីទទួលបានដីជាប្រពៃណីរបស់ពួកគេ និងសិទ្ធិរបស់ពួកគេក្នុងការផ្តល់ការយល់ព្រម
ឬមិនយល់ព្រមចំពោះការអភិវឌ្ឍន៍លើដីទាំងនោះ។

## ការពារសិទ្ធិស្ត្រី

ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជា បានឲ្យសច្ចាប័នលើអនុសញ្ញា របស់អង្គការសហប្រជាជាតិ
ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ហៅកាត់ថា ស៊ីដរ)
ព្រមគ្នានឹងកតិកា សញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
ដែលធានានូវសិទ្ធិមនុស្សរបស់ស្ត្រី រួមមាន សិទ្ធិលំនៅឋាន។ អនុសញ្ញានេះ
ដាក់កាតព្វឲ្យរដ្ឋាភិបាលគោរពសិទ្ធិលំនៅឋាន ឲ្យផ្តល់នីតិវិធីពិគ្រោះ
យោបល់ប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានដំណោះស្រាយ
នៅពេលដែលសិទ្ធិស្ត្រីទទួលរង នូវការរំលោភបំពាន។

ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី
ប្រទេសកម្ពុជា តម្រូវឲ្យ “លុបបំបាត់ការរើសអើង ទោះប្រព្រឹត្តដោយបុគ្គលណាម្នាក់
អង្គការណាមួយ ឬសហគ្រាសណាមួយក៏ដោយ”។
ចំណុចនេះរាប់បញ្ចូលទាំងការប្រឈមយ៉ាងខ្លាំងទៅនឹងការអនុវត្តជាទម្លាប់
ដែលគាំទ្រដល់គំនិតខុសឆ្គងមិនចេះផ្លាស់ប្តូរទាក់ទងនឹងយ៉េនឌ័ និងគំនិតខុសឆ្គងដែលថា
ភេទមួយទន់ខ្សោយជាងភេទមួយទៀត។

ស្ត្រីឈរនៅជួរមុខតស៊ូនឹងការរីករាលដាលនៃការបាត់បង់លំនៅឋាន
និងព្រៃឈើក្នុងប្រទេសកម្ពុជា។ ពួកគេ
ក៏ទទួលរងការលំបាកវេទនាដ៏ធំធេងផ្ទាល់ខ្លួនឯងផងដែរ ប្រសិនការតស៊ូរបស់ខ្លួនទទួលបរាជ័យ
គួបជាមួយនឹងផលប៉ះពាល់ដ៏អាក្រក់លើស្ថានភាពលំនៅឋាន មុខរបររកស៊ី
និងសុខមាលភាពផ្លូវកាយនិងចិត្តផ្ទាល់ខ្លួនឯងនិងក្រុមគ្រួសារ។
ស្ត្រីប្រឈមមុខនឹងរបាំងដ៏ធំធេងក្នុងការព្យាយាមទទួលយកបានយុត្តិធម៌តាមរយៈស្ថាប័នតុលាការនិងរដ្ឋបាលរបស់រដ្ឋ ដែលស្ថាប័នទាំងនេះគួរតែ ការពារនិងលើកកម្ពស់សិទ្ធិស្ត្រីទៅតាមច្បាប់
ប៉ុន្តែស្ថាប័នទាំងនេះកម្រធ្វើណាស់។ ផ្ទុយទៅវិញ ច្បាប់និងតុលាការ
ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់កៀបសង្កត់ បំបិទមាត់ជនទាំងឡាយណា
ដែលហ៊ានចេញមុខការពារសិទ្ធិរបស់ខ្លួន។

*នៅក្នុងរបាយការណ៍ ការបណ្តេញចេញ និងការតស៊ូនៅក្នុងប្រទេសកម្ពុជា ស្ត្រីប្រាំនាក់ប្រាប់រឿងរបស់ខ្លួន* (លិបិក្រម: ASA 23/006/2011),
អង្គការលើកលែងទោសអន្តរជាតិ បង្ហាញនូវ សោកនាដកម្ម ដែល
ជាទណ្ឌកម្មធ្លាក់មកលើប្រជាពលរដ្ឋជាច្រើនពាន់ៗនាក់នៅជុំវិញ ប្រទេស កម្ពុជា។
ខាងក្រោមនេះ គឺ ជាអនុសាសន៍ ដែលអង្គការលើកលែងទោសអន្តរជាតិដកស្រង់ពី
បទសម្ភាសន៍ជាមួយស្ត្រីទាំងនោះ និងការស្រាវជ្រាវថ្មីៗរបស់យើងខ្ញុំ
ទាក់ទងនឹងប្រធានបទនេះ។

វិច្ឆិកា ២០១១
លិបិក្រម: ASA 23/007/2011

# អនុសាសន៍

## ចំពោះរាជរដ្ឋាភិបាលកម្ពុជា

១. បញ្ចប់ការបណ្តេញចេញដោយបង្ខំ និងធានាថាជនប្រព្រឹត្តការបណ្តេញចេញដោយបង្ខំ ត្រូវចាប់ឲ្យទទួលខុសត្រូវក្រោមច្បាប់ រួមទាំងការការអនុវត្តទោសបញ្ញត្តិនៃច្បាប់ភូមិបាល (២០០១)។

២. ផ្អាករាល់ការបណ្តេញចេញមហាជនទាំងអស់ ទាល់តែ៖:

ក. បទបញ្ញត្តិហាមឃាត់ការបណ្តេញចេញដោយបង្ខំ ត្រូវបានអនុម័តនិងអនុវត្តក្រោមច្បាប់ជាតិ។

ខ. មានការអនុម័តមគ្គុទ្ទេសក៏តាក់តែងច្បាប់ ដោយដាក់ចេញនូវកិច្ចការពារផ្លូវច្បាប់ ដែលត្រូវគោរពអនុវត្តតាម មុននឹងមានការបណ្តេញចេញដោយបង្ខំណាមួយ។ មគ្គុទ្ទេសក៏ទាំងនេះ គួរផ្អែកលើគោលការណ៍ និងមគ្គុទ្ទេសក៏ជាមូលដ្ឋានស្តីពីការបណ្តេញចេញដោយបង្ខំ និងការជម្លៀសផ្អែកលើការអភិវឌ្ឍន៍ និងគួរអនុវត្តស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

៣. ធានាថា មានការវាយតំលៃអំពីផលប៉ះពាល់បរិស្ថាននិងសិទ្ធិមនុស្សយ៉ាងពេញលេញ មុនផ្តល់ដី សម្បទានណាមួយ បំណងកំណត់និងកាត់បន្ថយផលប៉ះពាល់លើសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ ដែលរស់នៅលើដីនោះ។ ប្រសិនមានការផ្តល់ដីសម្បទាន ការបណ្តេញចេញ ឬការបង្វែរដីណាមួយ ត្រូវអនុវត្តទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

៤. អនុម័ត និងផ្តល់អនុភាពដល់សេចក្តីព្រៀងគោលនយោបាយជាតិស្តីពីលំនៅឋាន

៥. ធានាថា រាល់ការបណ្តេញចេញ ត្រូវយកមកអនុវត្តសម្រាប់តែជាជម្រើសចុងក្រោយប៉ុណ្ណោះ និងត្រឹមតែបន្ទាប់ពីជម្រើសដែលអាចធ្វើទាំងអស់ក្រៅពីការបណ្តេញចេញ ត្រូវបានយកមកប្រើអស់ ក្នុងការពិគ្រោះយោបល់ពិតជាក់ស្តែងជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់។

៦. ធានាថាអាជ្ញាធរមានសមត្ថកិច្ច ទទួលបានការបណ្តុះបណ្តាលនិងបំពាក់បំប៉នត្រឹមត្រូវ ដើម្បីអនុវត្តការពិគ្រោះយោបល់ប្រកបដោយខ្លឹមសារ រួមមានការផ្តល់ព័ត៌មានសំខាន់ៗទាំងអស់ ដែលអ្នករង ប៉ះពាល់អាចទទួលរកបាន។

៧. បង្កើតនីតិវិធីសម្រាប់ស្ត្រី ដើម្បីបានចូលរួមក្នុងដំណើរកិច្ចពិភាក្សាគ្នាដោយស្មើភាពគ្នា និងក្នុងសេចក្តីសម្រេចចិត្តក្នុងគ្រួសារ ស្តីពីជ្រើសរើសយកសំណង ការតាំងទីលំនៅថ្មី ឬទទួលយកការគាំទ្រផ្សេងៗទៀត ឧទាហរណ៍ តម្រូវការស្នាមមេដៃទាំងបុរសនិងស្ត្រី លើការព្រមព្រៀងរើចេញ និងទទួលសំណង ឬតាំងទីលំនៅថ្មី។

៨. ក្នុងករណីដែលក្រុមគ្រួសារជ្រើសរើសយកការតាំងលំនៅថ្មី ត្រូវផ្តល់ឱកាសសម្រាប់ស្ត្រីចូលរួម ដោយស្មើភាពគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្ត ស្តីពីទីតាំងនិងស្ថានភាព នៃទីកន្លែងតាំងទីលំនៅថ្មី។ បើអាចធ្វើបាន គួរកំណត់ចំនួនទីតាំងទាំងឡាយណាដែលជាលទ្ធភាព ហើយត្រូវពិគ្រោះយោបល់អំពីទីកន្លែងទាំងនេះ ជាមួយអ្នកដែលរងផលប៉ះពាល់។ ទីតាំងលំនៅថ្មីទាំងអស់ ត្រូវអនុវត្តស្របតាមលក្ខណៈវិនិច្ឆ័យស្តីពីលំនៅឋានគ្រប់គ្រាន់ ដែលមានក្រោមច្បាប់អន្តរជាតិ។ គ្មានជនណាម្នាក់ត្រូវទទួលរងនូវការបង្ខិតបង្ខំឲ្យចាកចេញទៅកាន់ទីតាំងលំនៅនោះទេ រហូតទាល់តែមានការរៀបចំជាស្រេចសម្រាប់លំនៅឋានគ្រាប់គ្រាន់ អាចចូលទៅរកសេវាសំខាន់ៗ រួមមានទឹកស្អាត បង្គន់ អនាម័យ និងកន្លែងចោលសម្រាម ភ្លើងអគ្គីសនី ព្រមទាំងការទទួលបានសេវាសុខភាព និងសាលារៀន។ ត្រូវធានាថា ទីតាំងលំនៅថ្មីនឹងសម្រួលដល់ការទទួលបានសេវានានា សម្រាប់បុរសនិងស្ត្រី ដូចជាការមានការងារធ្វើ មានដីកសិកម្ម នេសាទ ឬប្រភពនៃមុខរបររកស៊ីសមរម្យផ្សេងៗ ដើម្បីគ្រួសារទាំងនោះមានលទ្ធភាពរកប្រាក់ចំណូល និងមានជីវភាពគ្រប់គ្រាន់។ នៅត្រង់ប្រកានេះ ត្រូវធានាថា សេវាទ្រទ្រង់របរចិញ្ចឹមជីវិតពាក់ព័ន្ធនិងប្រកបដោយប្រសិទ្ធភាព ត្រូវតែធ្វើឲ្យអាចរកបានសម្រាប់ទាំងបុរសនិងស្ត្រី ត្រូវដឹងថាស្ត្រីជាញឹកញយត្រូវការនូវការងារផ្ទះ។

៩. ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការសុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់ស្ត្រី នៅពេលនិងក្រោយពេលដំណើរការតាំងទីលំនៅថ្មី។ ប្រការនេះ រាប់បញ្ចូលទាំងឱកាសត្រួតពិនិត្យជាទៀងទាត់ ពីវេជ្ជបណ្ឌិត ដោយធានាដល់ការទទួលបានឱសថព្យាបាលដែលចាំបាច់ និងធានាថាគ្មានការបង្អាក់ដំណើរការទទួលបានអាហារូបត្ថម្ភ។ នៅកន្លែងដែលអាចធ្វើទៅបាន ដំណើការតាំងទីលំនៅថ្មី ត្រូវផ្តល់ឱកាសកែលម្អអាហារូបត្ថម្ភនិងសុខភាពរបស់ប្រជាពលរដ្ឋ ដែលស្ថានភាពពីមុនរបស់ពួកគេមានភាពខ្វះខាត។ ពង្រឹងបណ្តាញគាំទ្រក្នុងសហគមន៍ ជាពិសេសស្ត្រីភេទ និងជួយសម្រួលដល់ការទទួលបានសេវាសុខភាព ដូចជាអង្គការក្រៅរដ្ឋាភិបាល ដើម្បីឲ្យប្រជាពលរដ្ឋដែលជួបផលលំបាក អាចដោះស្រាយជំងឺថប់អារម្មណ៍ដោយសារការបណ្តេញចេញ។

១០. ក្នុងករណីគ្រួសារជ្រើសរើសយកសំណងជាប្រាក់ ត្រូវធានាអំពីចំនួនដែលផ្តល់ឲ្យនោះថាវាគ្រប់គ្រាន់ សម្រាប់ដោះដូរយកលំនៅឋានសមរម្យ និង/ឬយកដីធ្លីមានជីជាតិអាចផលិតបាន ព្រមទាំងថ្លៃឈ្នួលផ្សេងៗទៀត ដែលត្រូវទូទាត់ក្នុងដំណើរការផ្លាស់ប្តូរ។ បង្កើតយន្តការ ដើម្បីជំរុញឲ្យស្ត្រី ធ្វើការគ្រប់គ្រង ដោយស្មើភាពគ្នានឹងបុរស ទៅលើការសងសំណង។

១១. ក្រោយពេលការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ត្រូវឃ្លាំមើលស្ថានភាពរបស់ក្រុមគ្រួសារ ដើម្បីកំណត់ស្ត្រីដែលងាយរងគ្រោះពីអំពើហិង្សា